“ឯកសារនេះគឺជាការបកប្រែនៃឯកសារពេញច្បាប់ដែល HUD បានចេញផ្សាយ ។ HUD ផ្តល់ការបកប្រែនេះជូនអ្នក គឺគ្រាន់តែជាការងាយស្រួល ដើម្បីជួយអ្នកឲ្យយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប៉ុណ្ណោះ ។ កំណែជាភាសាអង់គ្លេសនៃឯកសារនេះ គឺជាឯកសារផ្លូវការ ពេញច្បាប់ និង ជាឯកសារត្រឹមត្រូវ ។ ឯកសារដែលបានបកប្រែនេះ គឺមិនមែនជាឯកសារផ្លូវការឡើយ” ។

ក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុង សហរដ្ឋ

# កញ្ចប់ឯកសារ សំរាប់ ការយល់ព្រមរបស់អ្នកដាក់ពាក្យសុំ/របស់អ្នកជួលផ្ទះ ចំពោះការបញ្ចេញព័ត៌មាន

នៅក្នុងកញ្ចប់នេះ មានឯកសារដូចតទៅ :

1. សន្លឹកភូតហេតុ **HUD-9887/A** ដែលរៀបរាប់ការបញ្ជាក់ជាចាំបាច់
2. ក្រដាសបំពេញ **HUD-9887** (ត្រូវបានចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះ)
3. ក្រដាសបំពេញ **HUD-9887-A** (ត្រូវបានចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះ និងម្ចាស់ទីលំនៅ)
4. ការបញ្ជាក់ជាប់ទាក់ទង (ត្រូវបានចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះ)

ក្រុមគ្រួសារនិមួយៗ ត្រូវតែទទួលសំណៅនៃសន្លឹកភូតហេតុ 9887/A ក្រដាសបំពេញ HUD-9887 និងក្រដាសបំពេញ HUD-9887-A ។

## សន្លឹកភូតហេតុ HUD-9887/A

# ការបញ្ជាក់ព័ត៌មាន បានផ្ដល់ដោយអ្នកដាក់ពាក្យសុំ និងអ្នកជួលផ្ទះនៃជំនួយទីលំនៅ

## ការបញ្ជាក់ជាប់ទាក់ទងនឹងអ្វីខ្លះ

ដើម្បីទទួលជំនួយទីលំនៅ អ្នកដាក់ពាក្យសុំ និងអ្នកជួលផ្ទះ ដែលមានអាយុយ៉ាងតិចបំផុត 18 ឆ្នាំ និងមេគ្រួសារនិមួយៗ ប្ដីឬប្រពន្ធ ឬក៏អនុមេគ្រួសារ ទោះជាអាយុប៉ុន្មានក៏ដោយ ត្រូវតែផ្ដល់ព័ត៌មានទៅឲ្យម្ចាស់ផ្ទះ ឬភ្នាក់ងារខាងការចាត់ចែង (Owner or Management Agent - O/A) ឬភ្នាក់ងារទីលំនៅសាធារណៈ (Public Housing Agency - PHA) នូវព័ត៌មានជាក់លាក់ ដែលបានបញ្ជាក់ដោយក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុង (Department of Housing and Urban Development - HUD) សហរដ្ឋ ។

ដើម្បីធ្វើឲ្យប្រាកដ ថាជំនួយបានប្រើដោយត្រឹមត្រូវ ច្បាប់រដ្ឋបាលសហព័ន្ធតម្រូវថា ព័ត៌មានដែលអ្នកផ្ដល់ឲ្យ ត្រូវតែបានបញ្ជាក់ ។ ព័ត៌មាននេះបានបញ្ជាក់ជាពីររបៀប ៖

1. HUD ឬ O/A និង PHA អាចនឹងបញ្ជាក់ព័ត៌មានដែលអ្នកផ្ដល់ឲ្យ ដោយពិនិត្យមើលឯកសារដែលបានរក្សាទុកដោយភ្នាក់ងារសាធារណៈណាមួយ (ដូចជា នាយកដ្ឋានសូស្យាល់សិគ្យួរិទី (Social Security Administration - SSA) ដោយភ្នាក់ងាររដ្ឋ ដែលរក្សាព័ត៌មានប្រាក់ឈ្នួល និងសំណងប្រាក់អត់ការធ្វើ និងដោយក្រសួងសុខាភិបាល និងសេវាមនុស្ស (Department of Health and Human Services - HHS) ទិន្នន័យរបស់បញ្ជីទូទាំងជាតិនៃការជួលបុគ្គលិកថ្មី (National Directory of New Hires - NDNH) ដែលរក្សា ព័ត៌មានប្រាក់ឈ្នួល, ការជួលបុគ្គលិកថ្មី, និងសំណងប្រាក់អត់ការធ្វើ) ។ មានតែ HUD (ប៉ុណ្ណោះទេ) អាចនឹងបញ្ជាក់ព័ត៌មាននៅក្នុងការធ្វើពន្ធដារបស់អ្នក ចេញពីក្រសួងហិរញ្ញវត្ថុ (Internal Revenue Service - IRS) សហរដ្ឋ ។ អ្នកផ្ដល់ការយល់ព្រមរបស់អ្នក ដើម្បីឲ្យបញ្ចេញព័ត៌មាននេះ តាមរយៈការចុះហត្ថលេខាក្រដាសបំពេញ HUD-9887 ។ មានតែ HUD ឬ O/A និង PHA ប៉ុណ្ណោះទេ អាចទទួលព័ត៌មានដែលបានអនុញ្ញាតដោយក្រដាសបំពេញនេះ ។

2. O/A ត្រូវតែបញ្ជាក់ព័ត៌មាន ដែលបានប្រើដើម្បីអនុម័តសិទ្ធិទទួលរបស់អ្នក និងចំនួនថ្លៃជួលផ្ទះដែលអ្នកត្រូវបង់ ។ អ្នកផ្ដល់ការយល់ព្រមរបស់អ្នក ដើម្បីបញ្ចេញព័ត៌មាននេះ តាមរយៈការចុះហត្ថលេខាក្រដាសបំពេញ HUD-9887 ក្រដាសបំពេញ HUD-9887-A និងក្រដាសបំពេញការបញ្ជាក់បុគ្គលម្នាក់ៗ និងការយល់ព្រម ដែលពាក់ព័ន្ធដល់អ្នក ។ ច្បាប់រដ្ឋបាលសហព័ន្ធដាក់កំរិតទៅលើប្រភេទព័ត៌មានស្ដីអំពីរូបអ្នក ដែល O/A អាចទទួល ។ ចំនួនប្រាក់ចំណូលដែលអ្នកទទួល ជួយអនុម័តចំនួនថ្លៃជួលផ្ទះ ដែលអ្នកនឹងត្រូវបង់ ។ O/A នឹងបញ្ជាក់ប្រភពប្រាក់ចំណូលទាំងអស់ ដែលអ្នករាយការណ៍ ។ មានការអនុគ្រោះខ្លះ ដែលបន្ថយប្រាក់ចំណូល បានប្រើក្នុងការអនុម័តថ្លៃជួលរបស់អ្នកជួលផ្ទះ ។

   **ឧទាហរណ៍ ៖** អ្នកស្រី សំណាង មានអាយុ 62 ឆ្នាំ ។ អាយុរបស់គាត់អាចទទួលការអនុគ្រោះថ្លៃពេទ្យ ។ ប្រាក់ចំណូលជាប្រចាំឆ្នាំរបស់គាត់នឹងបានកែសម្រួល ពីព្រោះការអនុគ្រោះនេះ ។ ពីព្រោះតែការចំណាយថ្លៃពេទ្យរបស់អ្នកស្រីសំណាង នឹងជួយអនុម័តចំនួនថ្លៃជួលផ្ទះដែលគាត់ត្រូវបង់ ម៉្លោះហើយ O/A ត្រូវបញ្ជាក់ការចំណាយថ្លៃពេទ្យអ្វីមួយដែលគាត់រាយការណ៍ ។

   **ឧទាហរណ៍ ៖** លោក អភ័ព្វ ពុំអាចទទួលការអនុគ្រោះថ្លៃពេទ្យទេ ពីព្រោះគាត់ពុំមានអាយុយ៉ាងតិចបំផុត 62 ឆ្នាំ ហើយគាត់ក៏មិនពិការ ឬមានភាពពិការឡើយ ។ ពីព្រោះគាត់ពុំមានសិទ្ធិទទួលការអនុគ្រោះថ្លៃពេទ្យ ម៉្លោះហើយចំនួននៃការចំណាយថ្លៃពេទ្យរបស់គាត់ មិនផ្លាស់ប្ដូរចំនួនថ្លៃជួលផ្ទះដែលគាត់ត្រូវបង់ឡើយ ។ ដោយសារហេតុនេះ O/A មិនអាចសួរលោក អភ័ព្វ អំពីការចំណាយថ្លៃពេទ្យសោះ ហើយក៏មិនអាចបញ្ជាក់ជាមួយនឹងភាគីទីបី អំពីការចំណាយថ្លៃពេទ្យដែលគាត់ចំណាយទេ ។

## ការការពារអតិថិជន

ព័ត៌មានដែល HUD បានទទួល ត្រូវបានការពារដោយក្រឹត្យភាពឯកជនរដ្ឋបាលសហព័ន្ធ (Federal Privacy Act) ។ ព័ត៌មានដែលបានទទួលដោយ O/A ឬដោយ PHA ត្រូវគោរព ច្បាប់ភាពឯកជនរដ្ឋ ។ បុគ្គលិករបស់ HUD ឬ O/A និង PHA ត្រូវទទួលទោសពិន័យ សំរាប់ការប្រើក្រដាសបំពេញការយល់ព្រមទាំងនេះដោយមិនត្រឹមត្រូវ ។ អ្នកមិនចាំបាច់ចុះហត្ថលេខាក្រដាសបំពេញ HUD-9887 ក្រដាសបំពេញ HUD-9887-A ឬក្រដាសបំពេញការយល់ព្រមបញ្ជាក់បុគ្គលម្នាក់ៗទេ នៅពេលក្រដាសបំពេញទាំងនេះបានឲ្យទៅអ្នក នៅពេលសំភាសន៍ការបញ្ជាក់ ឬការបញ្ជាក់សាថ្មី ។ អ្នកអាចយកក្រដាសទាំងនោះទៅផ្ទះ ដើម្បីអាន ឬពិភាក្សាជាមួយ នឹងភាគីទីបីតាមការជ្រើសរើសរបស់អ្នក ។ O/A នឹងប្រាប់ពេល កំណត់ថ្ងៃខែឆ្នាំ ដែលអ្នកអាចវិលមកចុះហត្ថលេខាក្រដាសបំពេញទាំងនេះ ។

បើអ្នកពុំអាចអាន និង/ឬ ចុះហត្ថលេខាក្រដាសបំពេញបានទេ ដោយព្រោះភាពពិការ នោះ O/A នឹងត្រូវធ្វើការសំរបសំរួលសមហេតុផល ឲ្យស្របតាមផ្នែក 504 នៃក្រឹត្យការស្ដារលទ្ធភាព (Rehabilitation Act) នៃឆ្នាំ 1973 ។ ការសំរបសំរួលបែបនោះ អាចនឹងរួមមាន ៖ ការមកជួបដល់ផ្ទះ នៅពេលភាពពិការរបស់អ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះ រាំងរាគាត់ឲ្យអាចមកការិយាល័យ បាន ដើម្បីបំពេញក្រដាសបំពេញ; អ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះ អនុញ្ញាតឲ្យមនុស្សម្នាក់ទៀត ដើម្បីចុះហត្ថលេខាជំនួសគាត់; និងសំរាប់ជនដែលពិការភ្នែក ការសំរបសំរួល អាចរួមមាននូវការផ្ដល់ក្រដាសបំពេញជាអក្សរពុម្ពខ្នាតធំ ឬអក្សរសំរាប់ជនពិការភ្នែក ឬការផ្ដល់អ្នកអានឲ្យស្ដាប់ ។

បើសមាជិកជាមនុស្សពេញវ័យនៃក្រុមគ្រួសាររបស់អ្នក ដោយព្រោះកាលៈទេសៈមិនល្អ ពុំអាចចុះហត្ថលេខាក្រដាសបំពេញ HUD-9887 ឬក្រដាសបំពេញការបញ្ជាក់បុគ្គលម្នាក់ៗ ឲ្យទាន់ពេលវេលាបានទេ O/A អាចនឹងកត់ជាឯកសារទុកក្នុងសំណុំរឿង អំពីមូលហេតុនៃការពន្យារពេល និងគំរោងការជាក់លាក់ ដើម្បីទទួលហត្ថលេខាដ៏ត្រឹមត្រូវ យ៉ាងឆាប់រហ័សបំផុត ។

O/A ត្រូវតែប្រាប់អ្នក ឬភាគីទីបីដែលអ្នកជ្រើសរើស អំពីការរកឃើញបានធ្វើ ជាលទ្ធផលចេញពីការបញ្ជាក់របស់ O/A ដែលបានអនុញ្ញាតតាមរយៈការយល់ព្រមរបស់អ្នក ។ O/A ត្រូវតែ ផ្ដល់ឱកាសឲ្យអ្នក ដើម្បីជំទាស់ការរកឃើញ ដោយស្របតាមសៀវភៅតម្រា HUD (HUD Handbook 4350.3) កំណែទី 1 ។ តែជាយ៉ាងណាមិញ ព័ត៌មានដែលបានទទួលតាមរយៈក្រដាសបំពេញ HUD-9887 ឬក្រដាសបំពេញ HUD-9887-A, HUD, O/A, ឬ PHA អាចនឹងជំរាបអ្នក អំពីការរកឃើញទាំងនេះ ។

O/A ត្រូវតែរក្សាសំណុំរឿងរបស់អ្នកជួលផ្ទះ ទុកនៅក្នុងទីកន្លែងមួយដែលធានាអះអាងភាពសំងាត់ ។ បុគ្គលិកណាម្នាក់នៃ O/A ដែលអាក់ខានរក្សាព័ត៌មានរបស់អ្នកជួលផ្ទះទុកជាសំងាត់ នឹងត្រូវប្រព្រឹត្តិតាមប្រការបញ្ញត្តិនៃក្រឹត្យភាពឯកជនរដ្ឋ និងត្រូវទទួលការប្ដឹងផ្ដល់ពីសំណាក់ HUD ។ អ្នកដាក់ ពាក្យសុំ ឬអ្នកជួលផ្ទះណាម្នាក់ ដែលបានប៉ះពាល់ដោយសារអំពើធ្វេសប្រហែស ចំពោះការបើក សំដែង ឬការប្រើប្រាស់ព័ត៌មានមិនត្រឹមត្រូវ ក៏អាចនឹងទទួលការប្ដឹងផ្ដល់ថ្នាក់ស៊ីវិល សំរាប់ការខាត បង់ និងស្វែងរកសំណងផ្សេងទៀត តាមភាពសមរម្យ ប្រឆាំងនឹងបុគ្គលិក ។

HUD-9887/A តម្រូវឲ្យ O/A ផ្ដល់ទៅក្រុមគ្រួសារនិមួយៗ នូវសំណៅនៃសន្លឹកភូតហេតុ និងក្រដាសបំពេញ HUD-9887 និង HUD-9887-A ព្រមទាំងក្រដាសបំពេញការយល់ព្រមពីបុគ្គលម្នាក់ៗ យ៉ាងត្រឹមត្រូវ ។ កញ្ចប់ដែលអ្នកនឹងទទួល នឹងរួមមាននូវឯកសារនៅខាងក្រោម ៖

1. **សន្លឹកភូតហេតុ HUD-9887/A ៖** រៀបរាប់អំពីសេចក្ដីតម្រូវសំរាប់ការបញ្ចេញព័ត៌មាន ដែលបុគ្គលម្នាក់ៗបានផ្ដល់ ដែលជាអ្នកដាក់ពាក្យសុំជំនួយទីលំនៅ ។ សន្លឹកភូតហេតុនេះ ក៏រៀបរាប់ពីការការពារអតិថិជន នៅក្រោមវិធីការបញ្ជាក់ផងដែរ ។
2. **ក្រដាសបំពេញ HUD-9887 ៖** អនុញ្ញាតឲ្យបញ្ចេញព័ត៌មាន រវាងភ្នាក់ងាររដ្ឋាភិបាល ។
3. **ក្រដាសបំពេញ HUD-9887-A ៖** រៀបរាប់អំពីសេចក្ដីតម្រូវនៃការបញ្ជាក់ពីភាគីទីបី ព្រមទាំងការការពារអតិថិជន ។
4. **សេចក្ដីបញ្ជាក់ការយល់ព្រមពីបុគ្គលម្នាក់ៗ ៖** បានប្រើដើម្បីបញ្ជាក់ព័ត៌មានជាប់ទាក់ទងដែលអ្នកដាក់ពាក្យសុំ/អ្នកជួលផ្ទះបានផ្ដល់ សំរាប់ការអនុម័តអំពីសិទ្ធិទទួល និងកំរិតនៃអត្ថប្រយោជន៍របស់គេ ។

### ផលវិបាក សំរាប់ការមិនចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម

បើអ្នកមិនព្រមចុះហត្ថលេខាក្រដាសបំពេញ HUD-9887 ឬក្រដាសបំពេញ HUD-9887-A ឬក៏ក្រដាសបំពេញការបញ្ជាក់បុគ្គលម្នាក់ៗទេ ការនេះអាចនឹងបណ្ដាលឲ្យជំនួយរបស់អ្នក ត្រូវបានបដិសេធ (សំរាប់អ្នកដាក់ពាក្យសុំ) ឬជំនួយរបស់អ្នកត្រូវបានបញ្ចប់ (សំរាប់អ្នកជួលផ្ទះ) ។ សូមមើលសេចក្ដីពន្យល់ថែមទៀត នៅក្នុងក្រដាសបំពេញ HUD-9887 និង 9887-A ។

បើអ្នកជាអ្នកដាក់ពាក្យសុំ ហើយជំនួយរបស់អ្នកត្រូវបានបដិសេធ សំរាប់មូលហេតុនេះ O/A ត្រូវតែជំរាបអ្នកអំពីមូលហេតុសំរាប់ការបដិសេធន៍ និងផ្ដល់ឱកាសឲ្យអ្នក ដើម្បីតវ៉ាការសំរេច ។

បើអ្នកជាអ្នកជួលផ្ទះ ហើយជំនួយរបស់អ្នកត្រូវបានបញ្ចប់ សំរាប់មូលហេតុនេះ O/A ត្រូវតែធ្វើតាមទំរង់ការដែលបានចែងក្នុងកិច្ចសន្យាជួល ។ នេះរួមទាំងឱកាសសំរាប់អ្នក ដើម្បីជួបជាមួយ O/A ។

### កម្មវិធីបានរ៉ាប់រងដោយសន្លឹកភូតហេតុនេះ

កម្មវិធីជំនួយថ្លៃជួលផ្ទះ (RAP)

ប្រាក់បន្ថែមថ្លៃជួលផ្ទះ

កម្មវិធីជំនួយបង់ប្រាក់ទីលំនៅផ្នែកទី 8 (បានគ្រប់គ្រងដោយការិយាល័យទីលំនៅ)

ផ្នែកទី 202

ផ្នែកទី 202 និង 811 PRAC

ផ្នែកទី 202/162 PAC

ផ្នែកទី 221(d)(3) ក្រោមអត្រាកំរិតការប្រាក់ទីផ្សារ

ផ្នែកទី 236

ភាពជាម្ចាស់ផ្ទះនៃគ្រឹហាពហុគ្រួសារ HOPE 2

O/A ត្រូវតែផ្ដល់សំណៅនៃសន្លឹកភូតហេតុ HUD នេះ ទៅឲ្យក្រុមគ្រួសារនិមួយៗ ។ សូមមើលសេចក្ដីណែនាំនៅក្នុងក្រដាសបំពេញ HUD-9887-A ។

# លិខិតជូនដំណឹង និងការយល់ព្រម សំរាប់ការបញ្ចេញព័ត៌មាន

ទៅឲ្យក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុង (HUD) និងទៅឲ្យម្ចាស់ផ្ទះ និងភ្នាក់ងារខាងការចាត់ចែង (O/A) ហើយនិងទៅឲ្យភ្នាក់ងារទីលំនៅ សាធារណៈ (PHA)

**ក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុង សហរដ្ឋ**

ការិយាល័យទីលំនៅ

ស្នងការទីលំនៅរដ្ឋបាលសហព័ន្ធ

| ការិយាល័យ HUD ដែលស្នើសុំការបញ្ចេញព័ត៌មាន (ម្ចាស់ផ្ទះ ត្រូវផ្តល់អាសយដ្ឋានពេញលេញ នៃការិយាល័យ HUD ក្នុងតំបន់ ដោយកាខ្ទងឲ្យចាប់អារម្មណ៍ទៅ : Director, Multifamily Division.) : | O/A ដែលស្នើសុំការបញ្ចេញព័ត៌មាន (ម្ចាស់ផ្ទះ ត្រូវផ្តល់ឈ្មោះ និងអាសយដ្ឋានពេញលេញរបស់ម្ចាស់ផ្ទះ) : | PHA ដែលស្នើសុំការបញ្ចេញព័ត៌មាន (ម្ចាស់ផ្ទះ ត្រូវផ្តល់ឈ្មោះ និងអាសយដ្ឋានពេញលេញរបស់ PHA ព្រមទាំងមុខតំណែងនៃនាយក ឬអ្នកគ្រប់គ្រង ។ បើពុំមានម្ចាស់ផ្ទះ PHA ឬអ្នកគ្រប់គ្រងម៉ៅការ សំរាប់គេហដ្ឋាននេះទេ ត្រូវគូសជាអក្សរ X ខ្វែងកាត់ពេញប្រអប់នេះ) : |
|---|---|---|
| | | |

**លិខិតជូនដំណឹងចំពោះអ្នកជួលផ្ទះ - ចូរកុំចុះហត្ថលេខាក្រដាសបំពេញនេះ បើកន្លែងចំហនៅខាងលើសំរាប់អង្គការដែលស្នើសុំការបញ្ចេញព័ត៌មាន បានទុកឲ្យនៅទំនេរ ។ អ្នកមិនចាំបាច់ចុះហត្ថលេខាក្រដាសបំពេញនេះ នៅពេលគេបានឲ្យអ្នកទេ ។ អ្នកអាចយកវាទៅផ្ទះ ដើម្បីអាន និងពិភាក្សាជាមួយនឹងភាគីទីបី តាមការជ្រើសរើសរបស់អ្នក ហើយវិលមកចុះហត្ថលេខាការយល់ព្រម នៅថ្ងៃខែឆ្នាំដែលអ្នកបានព្រមព្រៀងជាមួយនឹងម្ចាស់ ទីលំនៅ/អ្នកចាត់ចែងការ ។**

**អាជ្ញាធរ :** ផ្នែកទី 217 នៃក្រឹត្យបង្រួបបង្រួមការចាត់ទុកដោយឡែក (Consolidated Appropriations Act) នៃឆ្នាំ 2004 (Pub L. 108-199) ។ ច្បាប់នេះអាចរកឃើញនៅលេខ 42 U.S.C.653(J) ។ ច្បាប់នេះអនុញ្ញាត HHS ឲ្យបើកសំដែងព័ត៌មានទៅក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុង (HUD) ក្នុងចំណែក NDNH នៃ “ទីកន្លែង និងប្រព័ន្ធការប្រមូលកំណត់ត្រា” សំរាប់គោលបំណងនៃការបញ្ជាក់ការងារ និងប្រាក់ចំណូរបស់បុគ្គលម្នាក់ៗ ដែលចូលរួមក្នុងកម្មវិធីបានបញ្ជាក់ ហើយនិងបន្ទាប់ពីការយកគ្រឿងសំគាល់មនុស្សចេញ ដើម្បីធ្វើការវិភាគនៃ របាយការណ៍ការងារ និងប្រាក់ចំណូលរបស់បុគ្គលទាំងនេះ ។ ព័ត៌មានអាចនឹងបានបើកសំដែងដោយលេខាធិការនៃ HUD ទៅឲ្យម្ចាស់ផ្ទះឯកជន ឬភ្នាក់ងារខាងការចាត់ចែង និង អ្នកគ្រប់គ្រងកុងត្រា នៅក្នុងការគ្រប់គ្រងនៃជំនួយថ្លៃជួលទីលំនៅ ។

ផ្នែកទី 904 នៃក្រឹត្យការកែប្រែជំនួយអនាល័យ Stewart B. McKinney (Stewart B. McKinney Homeless Assistance Amendments Act) នៃឆ្នាំ 1988 ដូចបានកែប្រែដោយផ្នែកទី 903 នៃក្រឹត្យវឌ្ឍនកម្មទីលំនៅ និងសហគមន៍ នៃឆ្នាំ 1992 និងផ្នែកទី 3003 នៃក្រឹត្យព្រមព្រៀងចំរុះពីការសំរុះសំរួលថវិកា (Omnibus Budget Reconciliation Act) នៃឆ្នាំ 1993 ។ ច្បាប់នេះអាចរកឃើញនៅលេខ 42 U.S.C. 3544 ។ ច្បាប់នេះតម្រូវឲ្យអ្នកចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម ដើម្បីអនុញ្ញាតឲ្យ : (1) HUD និង PHA ដើម្បីសុំព័ត៌មានប្រាក់ឈ្នួល និងព័ត៌មានការទាមទារសំណងប្រាក់អត់ការធ្វើ ពីភ្នាក់ងាររដ្ឋដែលទទួលខុសត្រូវសំរាប់ការក្សាទុកព័ត៌មាននោះ; (2) HUD, O/A និង PHA ដែលទទួលខុសត្រូវ សំរាប់ការអនុម័តសិទ្ធិទទួល ដើម្បីបញ្ជាក់ព័ត៌មានប្រាក់ខែ និងប្រាក់ឈ្នួល ជាប់ទាក់ទិនសិទ្ធិទទួល ឬកំរិតនៃអត្ថប្រយោជន៍របស់អ្នកដាក់ពាក្យសុំ ឬរបស់អ្នកចូលរួម; (3) HUD ដើម្បីស្នើ សុំព័ត៌មានពន្ធដារខ្លះ អំពីនាយកដ្ឋានសូស្យាល់សឺគួរិទី (Social Security Administration - SSA) សហរដ្ឋ និងក្រសួងហិរញ្ញវត្ថុ (Internal Revenue Service - IRS) សហរដ្ឋ ។

**គោលបំណង :** តាមរយៈការចុះហត្ថលេខាក្រដាសបំពេញនេះ អ្នកអនុញ្ញាតឲ្យ HUD ឬ O/A ដែលមានឈ្មោះនៅខាងលើ និង PHA ស្នើសុំព័ត៌មានប្រាក់ចំណូល ពីភ្នាក់ងាររដ្ឋាភិបាល ដែលមានកត់ក្នុងក្រដាសបំពេញ ។ HUD ឬ O/A និង PHA ត្រូវការព័ត៌មាននេះ ដើម្បីបញ្ជាក់ប្រាក់ ចំណូលក្រុមគ្រួសាររបស់អ្នក ដើម្បីឲ្យប្រាកដថាអ្នកមានសិទ្ធិទទួលអត្ថប្រយោជន៍ជំនួយទីលំនៅ ហើយថាអត្ថប្រយោជន៍ទាំងនេះបានលៃលកត្រឹមត្រូវតាមកំរិត ។ HUD ឬ O/A និង PHA អាចនឹងចូលរួមក្នុងកម្មវិធីផ្គូរផ្គងកុំព្យូទ័រ ជាមួយនឹងប្រភពទាំងនេះ ដើម្បីបញ្ជាក់សិទ្ធិទទួល និងកំរិតនៃអត្ថប្រយោជន៍របស់អ្នក ។ ក្រដាសបំពេញនេះ ក៏អនុញ្ញាតឲ្យ HUD ឬ O/A និង PHA ស្វែងប្រាក់ឈ្នួល ឬការជួលបុគ្គលិកថ្មី (W-4) និងព័ត៌មានការទាមទារប្រាក់អត់ការធ្វើ ពីក្រុមហ៊ុនការងារបច្ចុប្បន្ន ឬពីអតីតកាល ដើម្បីបញ្ជាក់ព័ត៌មានដែលបានទទួលតាមរយៈការផ្គូរផ្គងកុំព្យូទ័រ ។

**ការប្រើប្រាស់ព័ត៌មាន ត្រូវបានទទួល :** HUD គឺបានតម្រូវឲ្យការពារព័ត៌មានប្រាក់ចំណូលដែលខ្លួនទទួល ដោយប្រព្រឹត្តស្របតាមក្រឹត្យភាពឯកជន នៃឆ្នាំ 1974, 5 U.S.C. 552a ។ O/A និង PHA ក៏បានតម្រូវឲ្យការពារព័ត៌មានប្រាក់ចំណូលដែលខ្លួនទទួល ដោយប្រព្រឹត្តស្របតាមច្បាប់ភាពឯកជនអ្វីមួយជាធរមាន របស់រដ្ឋផងដែរ ។ បន្ទាប់ពីការទទួលព័ត៌មានដែល បានរ៉ាប់រងដោយលិខិតនៃការយល់ព្រមនេះមក HUD ឬ O/A និង PHA អាចនឹងជំរាបអ្នក ថាសិទ្ធិទទួល ឬកំរិតនៃជំនួយរបស់អ្នក គឺមិនច្បាស់ប្រាកដទេ ហើយត្រូវការឲ្យបានបញ្ជាក់ និងគ្មានអ្វីទៀតឡើយ ។

បុគ្គលិករបស់ HUD ឬ O/A និង PHA អាចនឹងទទួលទោសពិន័យ សំរាប់ការបើកសំដែងដោយមិនបានអនុញ្ញាត ឬការប្រើប្រាស់មិនត្រឹមត្រូវ នូវព័ត៌មានប្រាក់ចំណូលដែលបានទទួល ដោយសំអាងលើក្រដាសបំពេញការយល់ព្រម ។

**អ្នកណាត្រូវតែចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម :**
សមាជិកនិមួយៗនៃក្រុមគ្រួសាររបស់អ្នក ដែលមានអាយុយ៉ាងតិចបំផុត 18 ឆ្នាំ និងមេគ្រួសារនិមួយៗ ប្តីឬប្រពន្ធ ឬអនុមេគ្រួសារ ទោះបើជា អាយុប៉ុន្មានក៏ដោយ ត្រូវតែចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម នៅពេលការបញ្ជាក់លើកដំបូង និងនៅពេលការបញ្ជាក់សាថ្មីម្តងៗ ។ ហត្ថលេខាបន្ថែមទៀតត្រូវតែបានទទួល ពីសមាជិកគ្រួសារជាមនុស្សទើបពេញវ័យ នៅពេលគេចូលរួមក្នុងក្រុមគ្រួសារ ឬនៅពេលសមាជិកក្រុមគ្រួសារគ្រប់អាយុ 18 ឆ្នាំ ។

មនុស្សដែលដាក់ពាក្យសុំ ឬទទួលជំនួយ នៅក្រោមកម្មវិធីខាងក្រោម គឺបានតម្រូវឲ្យចុះហត្ថលេខា ក្រដាសបំពេញការយល់ព្រម :

កម្មវិធីជំនួយថ្លៃជួលផ្ទះ (RAP)

ប្រាក់បន្ថែមថ្លៃជួលផ្ទះ

កម្មវិធីជំនួយបង់ប្រាក់ទីលំនៅផ្នែកទី 8 (បានគ្រប់គ្រងដោយការិយាល័យទីលំនៅ)

ផ្នែកទី 202; ផ្នែកទី 202 និង 811 PRAC; ផ្នែកទី 202/162 PAC ផ្នែកទី 221(d)(3) ក្រោមអត្រាកំរិតការប្រាក់ទីផ្សារ

ផ្នែកទី 236

ភាពជាម្ចាស់ផ្ទះនៃគ្រឹហាពហុគ្រួសារ HOPE 2

**ការមិនព្រមចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម :** ការអាក់ខានរបស់អ្នក ដើម្បីចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម អាចនឹងបណ្តាលឲ្យមានការបដិសេធន៍ជំនួយ ឬទទួលការបញ្ចប់អត្ថប្រយោជន៍ជំនួយទីលំនៅ ។ បើអ្នកដាក់ពាក្យសុំត្រូវបានបដិសេធជំនួយសំរាប់មូលហេតុនេះ ម្ចាស់ផ្ទះត្រូវតែធ្វើតាមទំរង់ការនៃការជំរាបដំណឹង នៅក្នុងសៀវភៅតម្រា 4350.3 កំណែទី 1 ។ បើអ្នកជួលផ្ទះត្រូវបាន បដិសេធជំនួយសំរាប់មូលហេតុនេះ ម្ចាស់ផ្ទះ ឬភ្នាក់ងារខាងការចាត់ចែង ត្រូវតែធ្វើតាមទំរង់ការដែលបានចែងក្នុងកិច្ចសន្យាជួល ។

**សេចក្តីយល់ព្រម : ខ្ញុំយល់ព្រមអនុញ្ញាតឲ្យ HUD ឬ O/A ឬក៏ PHA ស្នើសុំ និងទទួលព័ត៌មានប្រាក់ចំណូល ពីភ្នាក់ងាររដ្ឋបាលសហព័ន្ធ និងរដ្ឋ ដែលមានកត់នៅខាងខ្នងនៃក្រដាសបំពេញនេះ សំរាប់គោលបំណងនៃការបញ្ជាក់សិទ្ធិទទួល និងកំរិតនៃអត្ថប្រយោជន៍របស់ខ្ញុំ នៅក្រោមកម្មវិធីជំនួយទីលំនៅ HUD ។**

**“តែកំណែកិច្ចសន្យាជួលជាភាសាអង់គ្លេសប៉ុណ្ណោះទេ ដែលត្រូវបានចុះហត្ថលេខា” ។**

“ឯកសារនេះគឺជាការបកប្រែនៃឯកសារពេញច្បាប់ដែល HUD បានចេញផ្សាយ ។ HUD ផ្តល់ការបកប្រែនេះជូនអ្នក គឺគ្រាន់តែជាការងាយស្រួល ដើម្បីជួយអ្នកឲ្យយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប៉ុណ្ណោះ ។ កំណែជាភាសាអង់គ្លេសនៃឯកសារនេះ គឺជាឯកសារផ្លូវការ ពេញច្បាប់ និង ជាឯកសារត្រួតត្រា ។ ឯកសារដែលបានបកប្រែនេះ គឺមិនមែនជាឯកសារផ្លូវការឡើយ”

## ភ្នាក់ងារ ត្រូវផ្តល់ព័ត៌មាន

ភ្នាក់ងាររដ្ឋខាងការប្រមូលប្រាក់ឈ្នួល ។ (HUD និង PHA) ។ ការយល់ព្រមនេះ គឺកំរិតចំពោះប្រាក់ឈ្នួល និងសំណងប្រាក់អត់ការធ្វើ ដែលអ្នកបានទទួលក្នុងកំឡុងរយៈពេល 5 ឆ្នាំកន្លងទៅ នៅពេលអ្នកបានទទួលអត្ថប្រយោជន៍ជំនួយទីលំនៅ ។

នាយកដ្ឋានសូស្យាល់សឹគួរិទី សហរដ្ឋ (តែ HUD ប៉ុណ្ណោះ) ។ ការយល់ព្រមនេះ គឺកំរិតចំពោះប្រាក់ឈ្នួល និងព័ត៌មានការងារខ្លួនឯង ពីក្រដាសបំពេញ W-2 បច្ចុប្បន្នរបស់អ្នក ។

បញ្ជីទូទាំងជាតិនៃការជួលបុគ្គលិកថ្មី ដែលមាននៅក្នុងប្រព័ន្ធកំណត់ត្រារបស់ក្រសួងសុខភាព និងសេវាមនុស្ស ។ ការយល់ព្រមនេះ គឺកំរិតចំពោះប្រាក់ឈ្នួល និងសំណងប្រាក់អត់ការធ្វើ ដែលអ្នកបានទទួលក្នុងកំឡុងរយៈពេល 5 ឆ្នាំកន្លងទៅ នៅពេលអ្នកបានទទួលអត្ថប្រយោជន៍ជំនួយទីលំនៅ ។

ក្រសួងហិរញ្ញវត្ថុសហរដ្ឋ (តែ HUD ប៉ុណ្ណោះ) ។ ការយល់ព្រមនេះ គឺកំរិតចំពោះព័ត៌មាន ដែលមាននៅក្នុងការធ្វើពន្ធដារបច្ចុប្បន្នរបស់អ្នក ។

ការយល់ព្រមនេះ គឺកំរិតចំពោះព័ត៌មាននៅខាងក្រោម ដែលអាចឃើញមាននៅក្នុងការធ្វើពន្ធដារបច្ចុប្បន្នរបស់អ្នក :

1099-S របាយការណ៍ សំរាប់អ្នកទទួលប្រាក់ចំណេញ ពីកិច្ចការលក់អចលនាទ្រព្យ

1099-B របាយការណ៍ សំរាប់អ្នកទទួលប្រាក់ចំណេញ ពីអ្នកជើងសារការលក់អចលនាទ្រព្យ និងកិច្ចការប្តូរទំនិញ

1099-A ព័ត៌មានត្រឡប់វិញ សំរាប់ការបានមក ឬការបាត់បង់ទ្រព្យសម្បត្តិដែលបិតថេរ

1099-G របាយការណ៍ សំរាប់អ្នកទទួលការបើកប្រាក់ខ្លះពីរដ្ឋាភិបាល

1099-DIV របាយការណ៍ សំរាប់អ្នកទទួលប្រាក់ចំណេញហ៊ុន និងការចែកហ៊ុន

1099 INT របាយការណ៍ សំរាប់អ្នកទទួលប្រាក់ចំណូលការប្រាក់

1099-MISC របាយការណ៍ សំរាប់អ្នកទទួលប្រាក់ចំណូលផ្សេងៗទៀត

1099-OID របាយការណ៍ សំរាប់អ្នកទទួលការចុះតម្លៃដើមឲ្យ

1099-PATR របាយការណ៍ សំរាប់អ្នកទទួលការចែកចំណែកហ៊ុនត្រូវបង់ពន្ធ បានទទួលពីសហករណ៍

1099-R របាយការណ៍ សំរាប់អ្នកទទួលគំរោងប្រាក់និវត្តន៍ W2-G

របាយការណ៍នៃការឈ្នះល្បែង

1065-K1 ដៃគូចំណែកប្រាក់ចំណូល, ប្រាក់ជឿ, ការកាត់ចេញ, ជាដើម ។

1041-K1 អ្នកទទួលកំរៃចំណែកប្រាក់ចំណូល, ប្រាក់ជឿ, ការកាត់ចេញ, ជាដើម ។

1120S-K1 ចំណែករបស់កូនហ៊ុន នៃប្រាក់ចំណូលត្រូវបង់ពន្ធដែលបានចែកចាយ, ប្រាក់ជឿ, ការកាត់ចេញ, ជាដើម ។

ខ្ញុំយល់ថាព័ត៌មានប្រាក់ចំណូល ដែលបានទទួលពីប្រភពទាំងនេះ នឹងបានប្រើសំរាប់បញ្ជាក់ព័ត៌មានដែលខ្ញុំផ្តល់ ក្នុងការអនុម័តអំពីសិទ្ធិទទួលជាលើកដំបូង ឬជាបន្តទៀត សំរាប់កម្មវិធីជំនួយទីលំនៅ និងកំរិតនៃអត្ថប្រយោជន៍ ។

គ្មានវិធានការអ្វីអាចបានចាត់ដើម្បីបញ្ចប់ បដិសេធ ផ្អាក ឬបន្ថយជំនួយដែលក្រុមគ្រួសាររបស់អ្នកទទួល ដោយបានសំអាងលើព័ត៌មានដែលបានទទួលអំពីអ្នក តាមរយៈការយល់ព្រមនេះទេ រហូតទាល់តែការិយាល័យ HUD ឬការិយាល័យលេខាធិការនៃអ្នកស៊ើបអង្កេត (Office of Inspector General - OIG) ឬក៏ PHA (តាមណាមួយដែលពាក់ព័ន្ធ) និង O/A បានបញ្ជាក់ដោយខ្លួនឯង : 1) ចំនួនប្រាក់ចំណូល, ប្រាក់ឈ្នួល, ឬសំណងប្រាក់អត់ការធ្វើ បានជាប់ទាក់ទង; 2) ថាតើអ្នកពិតជាមាន (ឬធ្លាប់មាន) លទ្ធភាពទទួលប្រាក់ចំណូលដូចជា ប្រាក់ឈ្នួល, ឬអត្ថប្រយោជន៍សំរាប់ប្រើដោយខ្លួនអ្នក; និង 3) រយៈពេល ឬរយៈពេលនៅពេល ឬដោយគោរពចំពោះចំនួនប្រាក់ ចំណូល, ប្រាក់ឈ្នួល, ឬអត្ថប្រយោជន៍បែបដូច្នោះ ដែលអ្នកពិតជាបានទទួល ។ ក្រដាសថតចំឡងនៃការយល់ព្រមដែលបានចុះហត្ថលេខា អាចនឹងបានប្រើសំរាប់ស្នើទៅភាគីទីបី ដើម្បីបញ្ជាក់ព័ត៌មានអ្វីមួយដែលបានទទួលតាមរយៈការយល់ព្រមនេះ (ដូចជា ក្រុមហ៊ុនការងារ) ។

HUD ឬ O/A និង PHA ត្រូវជំរាបអ្នក ឬភាគីទីបី ដែលអ្នកចាត់តាំង អំពីការរកឃើញដែលបានធ្វើយោងលើព័ត៌មានដែលបានបញ្ជាក់ តាមរយៈការយល់ព្រមនេះ និងត្រូវផ្តល់ឱកាសឲ្យអ្នក ដើម្បីជំទាស់ការរកឃើញដូច្នោះ ដោយស្របតាមសៀវភៅតម្រា 4350.3 កំណែទី 1 ។

បើសមាជិកនៃក្រុមគ្រួសារដែលបានតម្រូវឲ្យចុះហត្ថលេខាក្រដាសបំពេញនេះ ពុំអាចចុះហត្ថលេខាទាន់ពេលវេលាបានទេ ដោយព្រោះកាលៈទេសៈមិនល្អ O/A អាចនឹងកត់ជាឯកសារ ទុកក្នុងសំណុំរឿង អំពីមូលហេតុនៃការព្យារពេល និងគំរោងការជាក់លាក់ ដើម្បីទទួលហត្ថលេខាដ៏ត្រឹមត្រូវយ៉ាងឆាប់រហ័សបំផុត ។

ក្រដាសបំពេញការយល់ព្រមនេះ ផុតកំណត់ចំនួន 15 ខែ បន្ទាប់ពីបានចុះហត្ថលេខា ។

---

**ក្រឹត្យវិញ្ញត្តិភាពឯកជន ។** ក្រសួងវឌ្ឍនកម្មទីក្រុង និងទីលំនៅ (Department of Housing and Urban Development - HUD) បានទទួលអនុញ្ញាតឲ្យប្រមូលព័ត៌មាននេះ ដោយក្រឹត្យ ទីលំនៅសហរដ្ឋ (U.S. Housing Act) នៃឆ្នាំ 1937 ដូចបានកែប្រែ (42 U.S.C. 1437 et. seq.); ក្រឹត្យការរើបអូសទីលំនៅ និងទីក្រុង-ជនបទ (Housing and Urban-Rural Recovery Act) នៃឆ្នាំ 1983 (P.L. 98-181); ការកែប្រែបច្ចេកទេសវឌ្ឍនកម្មទីលំនៅ និងសហគមន៍ (Housing and Community Development Technical Amendments) នៃឆ្នាំ 1984 (P.L. 98-479); និងដោយក្រឹត្យវឌ្ឍនកម្មទីក្រុង និងសហគមន៍ (Housing and Community Development Act) នៃឆ្នាំ 1987 (42 U.S.C. 3543) ។ ព័ត៌មានដែល ត្រូវបានប្រមូលដោយ HUD ដើម្បីអនុម័តសិទ្ធិទទួលរបស់អ្នកដាក់ពាក្យសុំ ឲ្យយោបល់ទំហំគ្រឹហា និងចំនួនអ្នកជួលផ្ទះ ត្រូវតែបង់សំរាប់ថ្លៃជួល និងថ្លៃទឹកភ្លើង ។ HUD ប្រើព័ត៌មាននេះ ដើម្បីជួយក្នុងការចាត់ចែងភូមិគ្រឹះខ្លះរបស់ HUD ដើម្បីការពារផលប្រយោជន៍ប្រាក់កាសរបស់រដ្ឋាភិបាល និងដើម្បីបញ្ជាក់ភាពពិតប្រាកដនៃព័ត៌មានដែលបានផ្តល់ ។ HUD ឬម្ចាស់ផ្ទះ ឬ ភ្នាក់ងារខាងការចាត់ចែង (Owner or Management Agent - O/A) ឬភ្នាក់ងារទីលំនៅសាធារណៈ (Public Housing Agency - PHA) អាចនឹងធ្វើការផ្ទួរផ្ទងកុំព្យូទ័រ នូវព័ត៌មានដែលអ្នកផ្តល់ ។ ព័ត៌មាននេះអាចនឹងបានបញ្ចេញទៅឲ្យភ្នាក់ងាររដ្ឋបាលសហព័ន្ធ រដ្ឋ ឬភ្នាក់ងារក្នុងតំបន់ យ៉ាងត្រឹមត្រូវ នៅពេលដែលជាប់ទាក់ទង និងចំពោះការប្តឹងថ្នាក់ស៊ីវិល បទឧក្រិដ្ឋ ឬអ្នកស៊ើបអង្កេតបទបញ្ញត្តិ និងសាក្សីខាងដើមចោទ ។ តែជាយ៉ាងណាមិញ ព័ត៌មាននឹងមិនបានបើកសំដែង ឬបានបញ្ចេញទៅក្រៅពី HUD ទេ លើកលែងតែច្បាប់បានអនុញ្ញាត ឬបានតម្រូវ ។ អ្នកត្រូវតែផ្តល់ព័ត៌មានទាំងអស់ដែលបានស្នើ ។ ការមិនព្រមផ្តល់ព័ត៌មានអ្វីមួយ អាចនឹងបណ្តាលឲ្យមានការព្យារពេល ឬការបដិសេធន៍មិនយល់ព្រមនូវសិទ្ធិទទួលរបស់អ្នក ។

---

**ទោសពិន័យ សំរាប់ការប្រើសេចក្តីយល់ព្រមដោយមិនត្រឹមត្រូវ :**

HUD ឬ O/A និង PHA ណាមួយ (ឬបុគ្គលិកណាម្នាក់របស់ HUD ឬ O/A ឬ PHA) អាចនឹងទទួលទោសពិន័យ សំរាប់ការបើកសំដែងដោយមិនបានអនុញ្ញាត ឬការប្រើប្រាស់ ដោយមិនត្រឹមត្រូវ នូវព័ត៌មានដែលបានប្រមូល បានសំអាងលើក្រដាសបំពេញការយល់ព្រម ។

ការប្រើប្រាស់ព័ត៌មានដែលបានប្រមូល បានសំអាងលើក្រដាសបំពេញ HUD 9887 គឺបានកំរិតចំពោះគោលបំណងដែលបានយោងលើក្រដាសបំពេញ HUD 9887 ។ ជនណាម្នាក់ដែល ស្នើ ទទួល ឬបើកសំដែងព័ត៌មានអ្វីមួយដោយពុតបន្លំ ដោយចេតនា ឬដោយឆន្ទៈចិត្ត ជាប់ទាក់ទងនឹងអ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះ អាចនឹងត្រូវបានជាប់ទោសបទល្មើសជាមជ្ឈឹម និងបានផាកមិនលើសពី $5,000 ។

អ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះណាម្នាក់ ដែលបានប៉ះពាល់ដោយសារអំពើធ្វេសប្រហែស ចំពោះការបើកសំដែងព័ត៌មាន អាចនឹងទទួលការប្តឹងផ្តល់ថ្នាក់ស៊ីវិល សំរាប់ការខាតបង់ និងស្វែងរក សំណងផ្សេងទៀតតាមភាពសមរម្យ ប្រឆាំងនឹងអ្នកមុខអ្នកការ ឬបុគ្គលិករបស់ HUD ឬម្ចាស់ផ្ទះ ឬ PHA ដែលទទួលខុសត្រូវសំរាប់ការបើកសំដែងដោយមិនបានអនុញ្ញាត ឬការប្រើប្រាស់ដោយមិនត្រឹមត្រូវ ។

# ការយល់ព្រមរបស់អ្នកដាក់ពាក្យសុំ/របស់អ្នកជួលផ្ទះ ចំពោះការបញ្ចេញព័ត៌មាន

## ការបញ្ជាក់ដោយម្ចាស់ផ្ទះ នូវព័ត៌មានដែលបុគ្គលម្នាក់ៗបានផ្តល់ ដែលជាអ្នកដាក់ពាក្យសុំជំនួយទីលំនៅ

**ក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុង សហរដ្ឋ**
ការិយាល័យទីលំនៅ
ស្នងការទីលំនៅរដ្ឋបាលសហព័ន្ធ

### សេចក្តីណែនាំ សំរាប់ម្ចាស់ផ្ទះ

1. ផ្តល់ឯកសារដែលមានកត់នៅខាងក្រោម ទៅឲ្យអ្នកដាក់ពាក្យសុំ/អ្នកជួលផ្ទះ ដើម្បីចុះហត្ថលេខា ។ កឹប ឬកៀបឲ្យជាប់គ្នាទាំងអស់ ដាក់ជាមួយកញ្ចប់ តាមលំដាប់លំដោយដែលបានចុះរាយ ។
   a. សន្លឹកភូតហេតុ HUD-9887/A ។
   b. ក្រដាសបំពេញ HUD-9887 ។
   c. ក្រដាសបំពេញ HUD-9887-A ។
   d. ការបញ្ជាក់ដែលជាប់ទាក់ទង (សៀវភៅតម្រា HUD 4350.3 កំណែទី 1) ។

2. ជំរាបអ្នកដាក់ពាក្យសុំ និងអ្នកជួលផ្ទះ ដោយផ្ទាល់មាត់ថា :
   a. គេអាចយកក្រដាសបំពេញទាំងនេះទៅផ្ទះ ដើម្បីអាន និងពិភាក្សាជាមួយនឹងភាគីទីបី តាមការជ្រើសរើសរបស់គេ និងវិលមកចុះហត្ថលេខាវិញ នៅថ្ងៃខែឆ្នាំដែលគេបានព្រមព្រៀងជាមួយអ្នក, និង
   b. បើគេមានភាពពិការ ដែលរាំងរាគេអំពីការអាន និង/ឬ ការចុះហត្ថលេខានៃការយល់ព្រមអ្វីមួយ នោះអ្នកជាម្ចាស់ផ្ទះ គឺបានតម្រូវឲ្យផ្តល់ការសំរបសំរួលដោយសមហេតុផល ។

3. ម្ចាស់ផ្ទះ គឺបានតម្រូវឲ្យផ្តល់ជូនក្រុមគ្រួសារនិមួយៗ នូវសំណៅនៃសន្លឹកភូតហេតុ HUD9887/A ក្រដាសបំពេញ HUD-9887 និងក្រដាសបំពេញ HUD-9887-A បន្ទាប់ពីបានទទួលហត្ថលេខាដែលបានតម្រូវ ពីអ្នកដាក់ពាក្យសុំ/អ្នកជួលផ្ទះ ។ ម្ចាស់ផ្ទះក៏ត្រូវតែផ្តល់ទៅឲ្យអ្នកដាក់ពាក្យសុំ/អ្នកជួលផ្ទះ នូវសំណៅនៃក្រដាសបំពេញការបញ្ជាក់បុគ្គលម្នាក់ៗ ដែលបានចុះហត្ថលេខា តាមសំណូមពររបស់គេ ។

### សេចក្តីណែនាំ សំរាប់អ្នកដាក់ពាក្យសុំ និងអ្នកជួលផ្ទះ

ក្រដាសបំពេញ HUD-9887-A នេះ មានព័ត៌មានរបស់អតិថិជន និងការការពារ ជាប់ទាក់ទងការបញ្ជាក់របស់ HUD ដែលបានតម្រូវ ដែលម្ចាស់ផ្ទះត្រូវតែប្រព្រឹត្ត ។

1. អានសំភារៈនេះ ដែលពន្យល់ :
   - សេចក្តីតម្រូវរបស់ HUD ជាប់ទាក់ទងការបញ្ចេញព័ត៌មាន, និង
   - ការការពារអតិថិជនផ្សេងទៀត ។

2. ចុះហត្ថលេខា នៅទំព័រចុងក្រោយ ដែលបញ្ជាក់ថា :
   - អ្នកបានអានក្រដាសបំពេញនេះ, ឬ
   - ម្ចាស់ផ្ទះ ឬភាគីទីបី តាមការជ្រើសរើសរបស់អ្នក បានពន្យល់អ្នក, និង
   - អ្នកយល់ព្រមចំពោះការបញ្ចេញព័ត៌មាន សំរាប់គោលបំណង និងការប្រើប្រាស់ដែលបានរៀបរាប់ ។

### អាជ្ញាធរ សំរាប់សេចក្តីតម្រូវការយល់ព្រមរបស់អ្នកដាក់ពាក្យសុំ/អ្នកជួលផ្ទះ ចំពោះការបញ្ចេញព័ត៌មាន

ផ្នែកទី 904 នៃការកែប្រែក្រឹត្យជំនួយអនាល័យ Stewart B. McKinney (Stewart B. McKinney Homeless Assistance Amendments Act) នៃឆ្នាំ 1988 ដូចបានកែប្រែដោយផ្នែកទី 903 នៃក្រឹត្យវឌ្ឍនកម្មទីលំនៅ និងសហគមន៍ (Housing and Community Development Act) នៃឆ្នាំ 1992 ។ ច្បាប់នេះអាចរកឃើញនៅលេខ 42 U.S.C. 3544 ។

ដូច្នេះហើយ ច្បាប់នេះតម្រូវឲ្យអ្នកចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម ដើម្បីអនុញ្ញាតឲ្យម្ចាស់ផ្ទះ ស្នើសុំពីម្ចាស់ក្រុមហ៊ុនបច្ចុប្បន្ន ឬពីអតីតកាល ឲ្យបញ្ជាក់ព័ត៌មានប្រាក់ខែ និងប្រាក់ឈ្នួលជាប់ទាក់ទិនចំពោះសិទ្ធិទទួល និងកំរិតនៃអត្ថប្រយោជន៍របស់អ្នក ។ មិនតែប៉ុណ្ណោះសោត បញ្ញត្តិ HUD (លេខ 24 CFR 5.659 ព័ត៌មានគ្រួសារ និងការបញ្ជាក់) តម្រូវជាលក្ខខ័ណ្ឌនៃការទទួលជំនួយទីលំនៅ ដែលអ្នកត្រូវតែចុះហត្ថលេខាយល់ព្រម បានយល់ព្រមឲ្យ HUD និងការយល់ព្រមអនុញ្ញាតឲ្យការប្រមែប្រមូលព័ត៌មានដូច្នោះ នៃការដាក់ប្រាក់ក្នុងធនាគារ ឬភ្រាពប្រាក់ចំណូលឯកជនអ្វីមួយ ដើម្បីផ្តល់ព័ត៌មានដូច្នោះដែលជាការចាំបាច់ សំរាប់ការអនុម័តនូវសិទ្ធិទទួល ឬកំរិតនៃអត្ថប្រយោជន៍របស់អ្នក ។ នេះរួមទាំងព័ត៌មានដែលអ្នកបានផ្តល់ ដែលនឹងប៉ះពាល់ចំពោះចំនួនថ្លៃជួលដែលអ្នកត្រូវបង់ ។ ព័ត៌មានរួមមាននូវប្រាក់ចំណូល និងធនធាន ដូចជាប្រាក់ខែ ជំនួយវែលហ្វែរ និងការប្រាក់បានមកពីកុងសន្សំប្រាក់ទុក ។ វាក៏រួមមានការកែសំរួលប្រាក់ចំណូលរបស់អ្នកខ្លះ ដូចជាប្រាក់ឧបត្ថម្ភសំរាប់មនុស្សក្នុងបន្ទុក និងសមាជិកក្រុមគ្រួសារដែលមេគ្រួសារ ឬប្តីប្រពន្ធ ជាមនុស្សចាស់ដែលពិការ ឬមានភាពពិការ; និងប្រាក់ឧបត្ថម្ភ សំរាប់ការចំណាយមើលថែទាំកូន ការចំណាយថ្លៃពេទ្យ និងជំនួយការចំណាយខាងភាពពិការ ។

### គោលបំណង សំរាប់សេចក្តីតម្រូវការយល់ព្រម ចំពោះការបញ្ចេញព័ត៌មាន

តាមរយៈការចុះហត្ថលេខាក្រដាសបំពេញនេះ អ្នកអនុញ្ញាតឲ្យម្ចាស់ទីលំនៅនៃគេហដ្ឋាន ដែលអ្នកកំពុងដាក់ពាក្យសុំជំនួយ ដើម្បីស្នើសុំព័ត៌មានស្តីអំពីរូបអ្នក ពីភាគីទីបី ។ HUD តម្រូវឲ្យម្ចាស់ទីលំនៅ បញ្ជាក់ព័ត៌មានទាំងអស់ដែលអ្នកផ្តល់ ដែលប៉ះពាល់ដល់សិទ្ធិទទួល និងកំរិតនៃអត្ថប្រយោជន៍របស់អ្នក ដើម្បីធ្វើឲ្យប្រាកដថាអ្នកមានសិទ្ធិទទួលអត្ថប្រយោជន៍ជំនួយទីលំនៅ ហើយថាអត្ថប្រយោជន៍ទាំងនេះ បានលៃលកត្រឹមត្រូវតាមកំរិត ។ ម្ចាស់ទីលំនៅអាចនឹងផ្តល់ទៅ HUD ឬ PHA នូវព័ត៌មានដែលអ្នកបានបញ្ជូនមក និងព័ត៌មាន ដែលម្ចាស់ផ្ទះទទួល តាមរយៈការយល់ព្រមនេះ ទៅតាមសំណូមពររបស់ការិយាល័យ HUD ឬ PHA (ជាអ្នកគ្រប់គ្រងកុងត្រា) ។

### ការប្រើប្រាស់ព័ត៌មាន ត្រូវបានទទួល

បុគ្គលម្នាក់ៗដែលមានកត់ក្នុងក្រដាសបំពេញការបញ្ជាក់ អាចនឹងស្នើសុំ និងទទួលព័ត៌មានដែលបានស្នើតាមរយៈការបញ្ជាក់ ដោយគោរពតាមការកំរិតនៃក្រដាសបំពេញនេះ ។ HUD គឺបានតម្រូវឲ្យការពារព័ត៌មានប្រាក់ចំណូលដែលខ្លួនទទួល ដោយប្រព្រឹត្តស្របតាមក្រឹត្យភាពឯកជន នៃឆ្នាំ 1974, 5 U.S.C. 552a ។ ម្ចាស់ផ្ទះ និង PHA ក៏បានតម្រូវឲ្យការពារព័ត៌មានប្រាក់ចំណូលដែលខ្លួនទទួល ដោយប្រព្រឹត្តស្របតាមច្បាប់ភាពឯកជនអ្វីមួយជាធរមាន របស់រដ្ឋផងដែរ ។ ប្រសិនបើម្ចាស់ផ្ទះទទួលព័ត៌មានអំពីភាគីទីបី ដែលមិនត្រូវគ្នាជាមួយនឹងព័ត៌មាន ដែលអ្នកបានផ្តល់ទេ ម្ចាស់ផ្ទះគឺបានតម្រូវឲ្យជំរាបអ្នកជាលាយល័ក្ខណ៍អក្សរ ដែលកត់សំគាល់ព័ត៌មានបានជឿថាមិនត្រឹមត្រូវ ។ បើសិនជាមានបញ្ហាយ៉ាងនេះកើតឡើង អ្នកមានឱកាសជួបជាមួយម្ចាស់ផ្ទះ ដើម្បីពិភាក្សានូវភាពមិនត្រូវគ្នាអ្វីមួយ ។

### អ្នកណាត្រូវតែចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម

សមាជិកនិមួយៗនៃក្រុមគ្រួសាររបស់អ្នក ដែលមានអាយុយ៉ាងតិចបំផុត 18 ឆ្នាំ និងមេគ្រួសារនិមួយៗ ប្តីឬប្រពន្ធ ឬអនុមេគ្រួសារ ទោះជាអាយុប៉ុន្មានក៏ដោយ ត្រូវតែចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម នៅពេលការបញ្ជាក់លើកដំបូង និងនៅពេលការបញ្ជាក់សាថ្មីម្តងៗ បើសិនជាពាក់ព័ន្ធ ។ លើសពីនេះទៀត នៅពេលសមាជិកជាមនុស្សទើបពេញវ័យចូលរួមក្នុងក្រុមគ្រួសារ និងនៅពេលសមាជិកក្រុមគ្រួសារ គ្រប់អាយុ 18 ឆ្នាំ គេក៏ត្រូវតែចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម ដែលជាប់ទាក់ទងផងដែរ ។

មនុស្សដែលដាក់ពាក្យសុំ ឬទទួលជំនួយ នៅក្រោមកម្មវិធីខាងក្រោម ត្រូវតែចុះហត្ថលេខាក្រដាសបំពេញការយល់ព្រមដែលជាប់ទាក់ទង :

កម្មវិធីជំនួយថ្លៃជួលផ្ទះ (RAP)
ប្រាក់បន្ថែមថ្លៃជួលផ្ទះ
កម្មវិធីជំនួយបង់ប្រាក់ទីលំនៅផ្នែកទី 8 (បានគ្រប់គ្រងដោយការិយាល័យទីលំនៅ)
ផ្នែកទី 202
ផ្នែកទី 202 និង 811 PRAC
ផ្នែកទី 202/162 PAC
ផ្នែកទី 221(d)(3) ក្រោមអត្រាកំរិតការប្រាក់ទីផ្សារ
ផ្នែកទី 236
ភាពជាម្ចាស់ផ្ទះនៃគ្រឹហាពហុគ្រួសារ HOPE 2

## ការមិនព្រមចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម

ការអាក់ខានចុះហត្ថលេខាក្រដាសបំពេញការយល់ព្រមណាមួយដែលបានតម្រូវ អាចនឹងបណ្តាលឲ្យមានការបដិសេធន៍ជំនួយ ឬទទួលការបញ្ចប់អត្ថប្រយោជន៍ជំនួយទីលំនៅ ។ បើអ្នកដាក់ពាក្យសុំត្រូវបានបដិសេធជំនួយសំរាប់មូលហេតុនេះ O/A ត្រូវតែធ្វើតាមទំរង់ការនៃការជំរាបដំណឹងនៅក្នុងសៀវភៅតម្រា 4350.3 កំណែទី 1 ។ បើអ្នកជាអ្នកជួលផ្ទះត្រូវបានបដិសេធជំនួយសំរាប់មូលហេតុនេះ O/A ត្រូវតែធ្វើតាមទំរង់ការដែលបានចែងក្នុងកិច្ចសន្យាជួល ។

### លក្ខខ័ណ្ឌ

គ្មានវិធានការអ្វីអាចបានចាត់ដើម្បីបញ្ចប់ បដិសេធ ផ្អាក ឬបន្ថយជំនួយដែលក្រុមគ្រួសាររបស់អ្នកទទួល ដោយបានសំអាងលើព័ត៌មានបានទទួលអំពីអ្នក តាមរយៈការយល់ព្រមនេះទេ រហូតទាល់តែ O/A បានធ្វើការដោយខ្លួនឯង 1) បានបញ្ជាក់ព័ត៌មានដែលអ្នកបានផ្តល់ ដោយគោរពចំពោះសិទ្ធិទទួល និងកំរិតនៃអត្ថប្រយោជន៍របស់អ្នក និង 2) ដោយគោរពចំពោះប្រាក់ចំណូល (រួមទាំងប្រាក់ចំណូលរកបាន និងឥតរកបាន) ដែល O/A បានបញ្ជាក់ថាតើអ្នកពិតជាមាន (ឬធ្លាប់មាន) លទ្ធភាពទទួលប្រាក់ចំណូលដូច្នោះ សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងបានបញ្ជាក់រយៈពេល ឬរយៈពេលនៅពេល ឬដោយគោរពចំពោះប្រាក់ចំណូល ដូចជា ប្រាក់ឈ្នួល ឬអត្ថប្រយោជន៍ដែលអ្នកពិតជាបានទទួល ។

ក្រដាសថតចំឡងនៃការយល់ព្រមដែលបានចុះហត្ថលេខា អាចនឹងបានប្រើសំរាប់ស្នើសុំព័ត៌មានដែលបានអនុញ្ញាតដោយហត្ថលេខារបស់អ្នក នៅលើក្រដាសបំពេញការយល់ព្រមពីបុគ្គលម្នាក់ៗ ។ ការនេះនឹងកើតឡើង បើ O/A ពុំមានសេចក្តីយល់ព្រមការបញ្ជាក់បុគ្គលម្នាក់ៗមួយទៀតទេ ជាមួយនឹងហត្ថលេខាដើមទេ ហើយ O/A បានតម្រូវឲ្យផ្ញើសំណើមួយទៀត សំរាប់ការបញ្ជាក់ (ឧទាហរណ៍ ភាគីទីបីអាក់ខានតបឆ្លើយ) ។ បើមានបញ្ហានេះកើតឡើង O/A អាចនឹងដាក់ក្រដាសថតចំឡងនៃការយល់ព្រមនេះ ភ្ជាប់ជាមួយនឹងក្រដាសថតចំឡងនៃក្រដាសបំពេញការបញ្ជាក់បុគ្គលម្នាក់ៗ ដែលអ្នកចុះហត្ថលេខា ។ ដើម្បីជៀសវាងនូវការប្រើក្រដាសថតចំឡងទាំងនេះ O/A និងបុគ្គលម្នាក់ៗ អាចយល់ព្រមព្រៀងចុះហត្ថលេខាការយល់ព្រមលើសពីមួយ សំរាប់ប្រភេទនៃការបញ្ជាក់និមួយៗ ដែលត្រូវការ ។ O/A ត្រូវជំរាបអ្នក ឬភាគីទីបីដែលអ្នកចាត់តាំង អំពីការរកឃើញបានធ្វើដោយសំអាងលើព័ត៌មាន បានបញ្ជាក់តាមរយៈការយល់ព្រមនេះ និងត្រូវផ្តល់ឱកាសឲ្យអ្នក ដើម្បីជំទាស់ការរកឃើញដូច្នោះ ដោយប្រព្រឹត្តស្របតាមសៀវភៅតម្រា 4350.3 កំណែទី 1 ។

O/A ត្រូវតែផ្តល់ឲ្យអ្នក នូវព័ត៌មានដែលបានទទួលតាមរយៈការយល់ព្រមនេះ ដោយប្រព្រឹត្តស្របតាមច្បាប់ភាពឯកជនរដ្ឋ ។

បើសមាជិកនៃក្រុមគ្រួសារដែលបានតម្រូវឲ្យចុះហត្ថលេខា ពុំអាចចុះហត្ថលេខាក្រដាសបំពេញការយល់ព្រមដែលបានតម្រូវឲ្យទាន់ពេលវេលាបានទេ ដោយព្រោះកាលៈទេសៈមិនល្អ O/A អាចនឹងកត់ជាឯកសារទុកក្នុងសំណុំរឿង អំពីមូលហេតុនៃការព្យារពេល និងគំរោងការជាក់លាក់ដើម្បីទទួលហត្ថលេខាដ៏ត្រឹមត្រូវ យ៉ាងឆាប់រហ័សបំផុត ។

ការយល់ព្រមពីបុគ្គលម្នាក់ៗ ចំពោះការបញ្ចេញព័ត៌មាន ផុតកំណត់ចំនួន 15 ខែ បន្ទាប់ពីគេបានចុះហត្ថលេខា ។ O/A អាចនឹងប្រើក្រដាសបំពេញការយល់ព្រមពីបុគ្គលម្នាក់ៗទាំងនេះ ក្នុងកំឡុងរយៈពេល 120 ថ្ងៃ មុនរយៈពេលការបញ្ជាក់ ។ O/A ក៏អាចនឹងប្រើក្រដាសបំពេញទាំងនេះ ក្នុងកំឡុងរយៈពេលការបញ្ជាក់បានដែរ ប៉ុន្តែនៅក្នុងករណីដែល O/A បានទទួលព័ត៌មានដែលបញ្ជាក់ថាព័ត៌មានដែលអ្នកបានផ្តល់ ប្រហែលជាមិនត្រឹមត្រូវទេ ។ ការប្រើប្រាស់សំរាប់គោលបំណងផ្សេងៗទៀត ត្រូវបានហាមឃាត់ ។

O/A មិនអាចនឹងធ្វើការដេញដោលចំពោះព័ត៌មានដែលចាស់ជាង 12 ខែបានឡើយ លុះត្រាតែគាត់បានទទួលព័ត៌មានដែលមិនស្របគ្នា ហើយមានមូលហេតុឲ្យជឿថាព័ត៌មាន ដែលអ្នកបានផ្តល់មិនត្រឹមត្រូវទេ ។ បើមានការនេះកើតឡើង O/A អាចនឹងទទួលព័ត៌មានក្នុងពេល 5 ឆ្នាំកន្លងទៅនៅពេលអ្នកបានទទួលជំនួយ ។

**ខ្ញុំបានអាន និងបានយល់ដឹងនូវព័ត៌មាននេះ ស្តីពីគោលបំណង**
**និងការប្រើប្រាស់ព័ត៌មានដែលបាន បញ្ជាក់ ហើយយល់ព្រមឲ្យបញ្ចេញព័ត៌មាននោះ**
**សំរាប់គោលបំណង និងការប្រើប្រាស់វា ។**

**ខ្ញុំបានអាន និងបានយល់ដឹង អំពីគោលបំណងនៃការយល់ព្រមនេះ**
**និងការប្រើប្រាស់របស់វា**
**ហើយខ្ញុំយល់ថាការប្រើសេចក្តីយល់ព្រមនេះដោយមិនត្រឹមត្រូវ**
**អាចនាំឲ្យជាប់ទោសពៃរ៍ ចំពោះខ្លួនខ្ញុំ ។**

**“តែកំណែកិច្ចសន្យាជួលជាភាសាអង់គ្លេសប៉ុណ្ណោះទេ**
**ដែលត្រូវបានចុះហត្ថលេខា” ។**

### ទោសពិន័យ សំរាប់ការប្រើប្រាស់សេចក្តីយល់ព្រមនេះ ដោយមិនត្រឹមត្រូវ :

HUD ឬ និង O/A ណាមួយ (ឬបុគ្គលិករបស់ HUD ឬ និង O/A ណាម្នាក់) អាចនឹងទទួលទោសពិន័យ សំរាប់ការបើកសំដែងដោយមិនបានអនុញ្ញាត ឬការប្រើប្រាស់ដោយមិនត្រឹមត្រូវ នូវព័ត៌មានដែលបានប្រមូលបានសំអាងលើក្រដាសបំពេញការយល់ព្រម ។

ការប្រើប្រាស់ព័ត៌មានដែលបានប្រមូល បានសំអាងលើក្រដាសបំពេញ HUD 9887-A គឺបានកំរិតចំពោះគោលបំណងដែលបានយោងលើក្រដាសបំពេញ HUD 9887-A ។ ជនណាម្នាក់ដែលស្នើ ទទួល ឬបើកសំដែងព័ត៌មានអ្វីមួយដោយពុតបន្លំ ដោយចេតនា ឬដោយឆន្ទៈចិត្ត ជាប់ទាក់ទងនឹងអ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះ អាចនឹងត្រូវបានជាប់ទោសបទល្មើសជាមជ្ឈឹម និងបានផាកមិនលើសពី $5,000 ។

អ្នកដាក់ពាក្យសុំ ឬអ្នកជួលផ្ទះណាម្នាក់ ដែលបានប៉ះពាល់ដោយសារអំពើធ្វេសប្រហែស ចំពោះការបើកសំដែងព័ត៌មាន អាចនឹងទទួលការប្តឹងផ្តល់ថ្នាក់ស៊ីវិល សំរាប់ការខាតបង់ និងស្វែងរកសំណងផ្សេងទៀតតាមភាពសមរម្យ ប្រឆាំងនឹងអ្នកមុខអ្នការ ឬបុគ្គលិករបស់ HUD ឬ O/A ឬក៏ PHA ដែលទទួលខុសត្រូវសំរាប់ការបើកសំដែងដោយមិនបានអនុញ្ញាត ឬការប្រើប្រាស់ ព័ត៌មាន ដោយមិនត្រឹមត្រូវ ។